ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...០៧.សរ.....

## សារាចរ
## ស្តីពី
## ការបោសសម្អាតមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាមតាមខ្សែបន្ទាត់ព្រំដែន

កិច្ចការបោសសម្អាតមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម គឺជាសកម្មភាពមនុស្សធម៌ដែលធានាសុវត្ថិភាពជូនប្រជាជន រួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិនិងការកាត់បន្ថយភាពក្រីក្រ។ កន្លងមករាជរដ្ឋាភិបាលបានផ្សព្វផ្សាយនូវសារាចរណែនាំនិងគោលការណ៍ណែនាំជាបន្តបន្ទាប់ក្នុងគោលបំណងពន្លឿនវឌ្ឍនភាពក្នុងការអនុវត្តយុទ្ធសាស្ត្រជាតិសកម្មភាពមីននិងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ទី៩របស់ព្រះរាជាណាចក្រកម្ពុជាឲ្យសម្រេចបានជោគជ័យ។ ការបោសសម្អាតមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាមតាមខ្សែបន្ទាត់ព្រំដែនត្រូវបានពិនិត្យឃើញថាជាការផ្តល់ប្រយោជន៍យ៉ាងខ្លាំងដល់ប្រជាជនដែលរស់នៅតំបន់នោះ ហើយក៏ជាកាតព្វកិច្ចរបស់ព្រះរាជាណាចក្រកម្ពុជាក្នុងការអនុវត្តអនុសញ្ញាស្តីពីការហាមការប្រើប្រាស់ ការរក្សាទុក ការផលិត និងការផ្ទេរគ្រាប់មីនប្រឆាំងមនុស្សនិងការបំផ្លាញគ្រាប់មីនហៅកាត់ថាសន្ធិសញ្ញាអូតាវ៉ាដែលព្រះរាជាណាចក្រកម្ពុជាជារដ្ឋហត្ថលេខីផងដែរ។ ប៉ុន្តែការបោសសម្អាតនៅតំបន់ដែលព្រះរាជាណាចក្រកម្ពុជាមិនទាន់ឯកភាពក្នុងការកំណត់ខ្សែបន្ទាត់និងការបោះបង្គោលខណ្ឌសីមាព្រំដែនច្បាស់លាស់អាចបណ្តាលឲ្យមានផលប៉ះពាល់ច្រើនជាមួយប្រទេសជិតខាង ដែលទាមទារឲ្យមានវិធានការសមស្របមុននឹងអាចប្រព្រឹត្តទៅបាន។ ដើម្បីពង្រឹងបន្ថែមនូវប្រសិទ្ធភាពក្នុងការបោសសម្អាតមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាមតាមខ្សែបន្ទាត់ព្រំដែននិងរក្សាទំនាក់ទំនងល្អជាមួយប្រទេសជិតខាងរាជរដ្ឋាភិបាលសូមដាក់ចេញវិធានការដូចខាងក្រោម៖

១- គណៈកម្មាធិការជាតិទទួលបន្ទុកកិច្ចការព្រំដែន ត្រូវផ្តល់ជូនអាជ្ញាធរមីននូវផែនទីថតចម្លងទាំងឡាយណាដែលអាចប្រើប្រាស់ជាផ្លូវការបាន ដោយមានការទទួលស្គាល់ពីប្រទេសជាប់ព្រំដែនជាមួយព្រះរាជាណាចក្រកម្ពុជា ដើម្បីធ្វើការផ្ទៀងផ្ទាត់តំបន់ដែលមានផលប៉ះពាល់ដោយសារមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម។

២- អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកម្ចាត់មីននិងសង្គ្រោះជនពិការដោយសារមីន ត្រូវសហការជាមួយគណៈកម្មាធិការជាតិទទួលបន្ទុកកិច្ចការព្រំដែនជាប្រចាំ ដើម្បីផ្ទៀងផ្ទាត់ពីតំបន់ដែលមានផលប៉ះពាល់ដោយសារមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាមតាមខ្សែបន្ទាត់ព្រំដែន។

៣- រាល់ការបោសសម្អាតមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាមនៅតំបន់ដែលខ្សែបន្ទាត់ព្រំដែននៅមិនទាន់មានការឯកភាពគ្នាពីភាគីទាំងសងខាង ត្រូវសុំការអនុញ្ញាតជាមុនពីគណៈកម្មាធិការជាតិទទួលបន្ទុកកិច្ចការព្រំដែន តាមរយៈអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកម្ចាត់មីននិងសង្គ្រោះជនពិការដោយសារមីន។

៤- រដ្ឋបាលថ្នាក់ក្រោមជាតិមានភារកិច្ចទប់ស្កាត់រាល់ការបោសសម្អាតមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាមក្នុងតំបន់ដែលភាគីទាំងពីរនៅមិនទាន់ឯកភាពគ្នាក្នុងការកំណត់ខ្សែបន្ទាត់ព្រំដែនច្បាស់លាស់និងគ្មានការអនុញ្ញាតពីស្ថាប័នពាក់ព័ន្ធ ហើយត្រូវជូនដំណឹងមកអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកម្ចាត់មីននិងសង្គ្រោះជនពិការដោយសារមីននិងគណៈកម្មាធិការជាតិទទួលបន្ទុកកិច្ចការព្រំដែន ដើម្បីស្វែងរកវិធានការសមស្រប។

ទទួលបានសារាចរនេះ គ្រប់ក្រសួង ស្ថាប័ន គណៈកម្មាធិការជាតិទទួលបន្ទុកកិច្ចការព្រំដែន អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកម្ចាត់មីននិងសង្គ្រោះជនពិការដោយសារមីន អាជ្ញាធរថ្នាក់ក្រោមជាតិ ប្រតិបត្តិករបោសសម្អាតមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម ក្រុមហ៊ុនធ្វើអាជីវកម្មបោសសម្អាតមីននិងអង្គការពាក់ព័ន្ធត្រូវអនុវត្តឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។/.

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០២ ខែមីនា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល** :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់សាលារាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ